# Living the Lotus

## Buddhism in Everyday Life

1
2025
VOL. 232




Rissho Kosei-kai of Oklahoma

Living the Lotus
Vol. 232 (January 2025)

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

# សូមឱ្យម្នាក់ៗទៅជា「អូអាស៊ីស（Oasis）」

ព្រះគ្រូនីវ៉ាណូ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ




## ស្ថានីយ៍ដំបូងឬចំណុចចេញដំណើរដែលមានឈ្មោះថាចូលឆ្នាំថ្មី

សូមជូនពរឆ្នាំថ្មី។ នៅថ្ងៃដែលចាប់ផ្ដើមដំបូងនៃឆ្នាំហើយយើងអាចមកជួបជុំគ្នាបែបនេះនាំឱ្យគិតថាចូលឆ្នាំគឺជា "ស្ថានីយ៍ដំបូងឬចំណុចចេញដំណើរ" នៃរយៈពេលមួយឆ្នាំ។ ឆ្នាំថ្មីក៏ជាឱកាសដ៏ល្អប្រសើរមួយក្នុងការប្ដូរចិត្តគំនិតឱ្យថ្មីស្រស់ស្រាយ ដើម្បីធ្វើការសច្ចាថ្មី ផ្អែកទៅលើស្វ័យត្រិះរិះពីឆ្នាំមុន ដូចដែលកំណាព្យរបស់កវីសៃតូម៉ូគីជីចែងថា "នៅដើមឆ្នាំចូរយើងចងចាំរឿងមួយដែលយើងនឹកឃើញហើយអនុវត្តវា" ពោលគឺថានៅ"ស្ថានីយ៍ដំបូង"នេះ យើងគួរតែរៀបចំអីវ៉ាន់អីវ៉ាន់ដែលត្រូវយកទៅតាមខ្លួនឱ្យបានសព្វគ្រប់សម្រាប់ការធ្វើដំណើររយៈពេលមួយឆ្នាំ។ និយាយអ៊ីចឹងតើអ្នកទាំងអស់គ្នាមានបានសច្ចានឹងខ្លួនឯងថានឹង " ចងចាំអ្វីមួយទុកក្នុងចិត្តរហូតទៅថ្ងៃមុខ" ទេ ?

នេះដោយសារគុណបុណ្យលោកអ្នកទាំងអស់គ្នាខ្ញុំព្រះករុណាអាត្មាភាពបានអាយុគម្រប់ 88 វស្សាហើយៗខ្ញុំព្រះករុណាអាត្មាភាពគិតថាគឺជាអ្វីដែលគួរឱ្យដឹងគុណនិងរីករាយជាខ្លាំង។ ទោះជាយ៉ាងណាក៏ដោយមិនថាយើងមានអាយុប៉ុន្មាននោះទេធម្មជាតិរបស់មនុស្សគឺតែងតែមានគោលបំណង ចង់លូតលាស់ និងកែលម្អដូច្នេះខ្ញុំព្រះករុណាអាត្មាភាពគិតថាអាយុ៨៨ក៏ជាតំណាក់កាលមួយនៃជីវិតពោលគឺជា "តំណាក់ស្ថានីយ៍មួយដែលរថឈប់'ដើម្បីដាក់អ្នកដំណើរចុះឬឡើង ដែលជាចំណុចឆ្លងកាត់ដើម្បីបន្តដំណើរទៅស្ថានីយ៍ឯមុខទៀត ហើយនៅពេលដែលឡើងទួលមួយហើយក៏តោងតែឆ្ពោះទៅរកទួលមួយទៀតដែរ។ក្នុងន័យនេះឆ្នាំនេះក៏ដូចឆ្នាំមុនៗដែរខ្ញុំព្រះករុណាអាត្មាភាពសង្ឃឹមថានឹងអាចបន្តដំណើរទៅមុខនិងរីកចម្រើនដោយចងចាំទុកក្នុងចិត្តជានិច្ចនូវភាពឧស្សាហ៍,សេចក្ដីព្យា យាមនិងសមានចិត្តចំពោះអ្នកដទៃនិងខ្លួនឯង។

នេះគឺជាផែនការប្រចាំឆ្នាំមិនដែលប្រែប្រួលរបស់ខ្ញុំព្រះករុណាអាត្មាភាព។ ក៏ប៉ុន្តែក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ខ្ញុំព្រះករុណាអាត្មាភាពមានក្ដីព្រួយបារម្ភជាពិសេសអំពីសារៈសំខាន់នៃការអភិវឌ្ឍន៍ធនធានមនុស្ស។

ភពទឹកពណ៌ខៀវគឺផែនដីដែលអណ្ដែតក្នុងចក្រវាល ,ព្រមទាំងបរិស្ថាននៅក្នុងភពផែនដីនេះកាន់តែយ៉ាប់យ៉ឺនទៅៗពីមួយឆ្នាំទៅមួយឆ្នាំ ហើយជម្លោះ និងសង្គ្រាមនៅតែបន្តរវាងមនុស្សនិងមនុស្សដែលរស់នៅទីនោះ... នៅពេលខ្ញុំព្រះករុណាអាត្មាភាពគិតពីការពិតនេះ ខ្ញុំព្រះករុណាអាត្មាភាពក៏នឹកឃើញពីសារៈសំខាន់ ក្នុងការធ្វើផែនការផ្ទាល់ខ្លួនរបស់យើងម្នាក់ ៗសម្រាប់ការអភិវឌ្ឍន៍ធនធានមនុស្សដែលមានមនុស្សធម៌ មានបេះដូងទូលាយអាចយល់ពីការ

ឈើចាប់របស់អ្នកដទៃ។ នេះក៏ព្រោះតែយើងម្នាក់ៗមានទំនួលខុសត្រូវក្នុងការបន្សល់ទុកនូវផែនដីដ៏ស្រស់ស្អាត ហើយមានភាពសុខដុមរមនាសម្រាប់បេះដូងមនុស្ស និងបរិ ស្ថាន។

## ដាំដើមឈើក្នុងចិត្ត

នៅពេលដែលយើងខិតជិតដល់ខួបលើកទី 100 នៃការបង្កើតសមាគមរបស់យើង ខ្ញុំព្រះករុណាអាត្មាភាពបាននិយាយពីមុនមកថា យើងចង់ផ្តល់សារៈសំខាន់ទៅលើ "ការដាំ  បណ្តុះមនុស្ស" ។ តាមទស្សនៈរបស់យើងជាពុទ្ធសាសនិក តាមរយៈការប្រៀនប្រដៅរបស់ព្រះពុទ្ធ យើងមិនត្រឹមតែចង់ធ្វើឱ្យខ្លួនយើងសប្បាយរីករាយមានសុភមង្គលតែប៉ុណ្ណោះទេ គឺថែមទាំងចង់ឱ្យគ្រួសារយើង ប្រជាជនក្នុងសហគមន៍យើង និងមនុស្សក្នុងលោកដែលនៅឆ្ងាយពីយើងមានសុភមង្គលផងដែរមានន័យថាបណ្តុះបណ្តាលព្រះពោធិសត្វ ឬមនុស្សដែលមានសមានចិត្តយកចិត្តទុកដាក់ជាទីបំផុតទៅលើអ្នកដែលត្រូវការៗសង្គ្រោះ។

នៅទីដែលមានព្រះពោធិសត្វដែលមានចិត្តទូលាយគង់នៅពោលគឺ□អូអាស៊ីស (Oasis) ជាទីនាំឱ្យស្ងប់ចិត្ត□ ដែលធ្វើឲ្យមនុស្សមានសេចក្តីសុខ និងសេចក្តីស្ងប់ក្នុងចិត្តពោលគឺអូអាស៊ីសទីនោះនឹងក្លាយទៅជាអូអាស៊ីស (ទីកន្លែងដែលធ្វើឲ្យមនុស្សមានសេចក្តីសុខ និងសេចក្តីស្ងប់ក្នុងចិត្ត) ។ម្នាលអ្នកទាំងឡាយ ខ្ញុំព្រះករុណាអាត្មាភាពតែងតែស្រមៃឃើញថាមានអូអាស៊ីស

(Oasis) ដែលមនុស្សទាំងឡាយនិងសមណៈ (ពោលគឺអ្នកដែលមានជំនឿដូចគ្នា) មកជួបជុំគ្នាកើតឡើង ហើយអូអាស៊ីស

(Oasis) នេះនឹងរីកធំរាលដាលទៅជាកន្លែងចិញ្ចឹមបេះដូងរបស់មនុស្ស។ ជាការពិតណាស់ នេះមិនមែនជាគោលដៅនៃការអភិ   វឌ្ឍន៍សមាគមរបស់យើងនោះទេ ប៉ុន្តែជាឧត្តមគតិដែលកើតចេញពីការបារម្ភចំពោះអនាគតនៃផែនដី និងមនុស្សជាតិ។

កាលពីមុនដូចដែលសូម្បីតែព្រះពុទ្ធក៏មានមនុស្សដែលមានចេតនានឹងធ្វើគតដែរ តាំងពីមានកំណើតរបស់មនុស្សមក ចំណង់របស់មនុស្សគឺចង់ធ្វើអ្វីដែលចិត្តគេចង់ហើយចំណង់នេះមិនដែលប្រែប្រួលទេ  លើសពីនេះទៅទៀត បំណងប្រាថ្នា តណ្ហានិងអំពើហឹង្សារបស់មនុស្សចេះតែបន្តកើនឡើងហើយរីករាលដាលធំឡើងៗ។

ក៏ប៉ុន្តែដូចជា សេចក្តីប៉ងប្រាថ្នាដែលគ្មានទីបញ្ចប់នៃមនុស្សដែរ ដូនតារបស់យើងបានបង្រៀនយើងថា "ឧត្តមគតិក៏ត្រូវតែគ្មានដែនកំណត់ដែរ"។ គ្មានការរីកចំរើនឯណាដែលកើតមានឡើងដោយគ្មានឧត្តមគតិទេ ហើយជីវិតមនុស្សគឺជាការងារធ្វើឱ្យឧត្តមគតិក្លាយទៅជាការពិត។ យើងម្នាក់ៗឥឡូវនេះកំពុងឈរនៅចំណុចចាប់ផ្តើមនៃការធ្វើឱ្យឧត្តមគតិនោះក្លាយទៅជាការពិត។ដំបូងឡើងយើងខ្លួនយើងត្រូវក្លាយទៅជា អូអាស៊ីស (Oasis) ដែលមានដើមឈើមួយដើម នៅក្នុងគ្រួសាររបស់ខ្លួន បន្ទាប់មកគ្រួសាររបស់អ្នកក្លាយជាអូអាស៊ីស ( Oasis) សម្រាប់អ្នកជិតខាងរបស់អ្នក។

នៅក្នុងព្រះពុទ្ធសាសនា គេចាត់ទុកថាការសម្លាប់ជីវិតអ្នកដទៃ ជាអំពើបាបដ៏ធ្ងន់បំផុត។ ដូច្នេះយើងតោងតែរំឭកខ្លួនឯងជារៀងរាល់ថ្ងៃអំពីគុណតម្លៃនៃជីវិត និងការគិតពីចិត្តអ្នកដទៃដោយតម្រូតខ្លួនឯងទៅនឹងរូបអ្នកនោះដូចភាសាខ្មែរនិយាយថារូបឯងរូបគេតាមរយៈការអនុវត្តន៍សេចក្តីមេត្តាករុណា ដោយទង្វើ និងពាក្យសម្តីដែលប្រកបទៅដោយសមានចិត្តទៅកាន់អ្នកដ៏ទៃ ។ ការអនុវត្តន៍បែបនេះក៏នាំទៅរកការគិតពីប្រយោជន៍អ្នកដទៃ ហើយយើងអាចទៅជាអ្នកដាំស្មៅឬដើមឈើសម្រាប់អូអាស៊ីសថ្មីនៅក្នុងចិត្តរបស់មនុស្សដទៃ។ ដោយវិធីនេះ នៅពេលដែលយើង បង្កើតមិត្តជាមួយមនុស្សជាច្រើន ហើយខំរស់ជីវិតមួយឱ្យពេញលេញជាមួយគ្នាក្នុងបច្ចុប្បន្ន ប្រកបដោយការដឹងគុណគ្នាទៅវិញទៅមកនេះ ព្រះស្ថាបនិកកៃសូសាម៉ាបានប្រើពាក្យថាជា "ពិធីថ្វាយតង្វាយចំពោះទំពាំងដែលនឹងស្នងឫស្សីនាអនាគត" ហើយក៏ជា "ការថ្វាយតង្វាយចំពោះអនាគត



# Rissho Kosei-kai International

## Make Every Encounter Matter




## A Global Buddhist Movement




| Information about local Dharma centers | facebook | X |
|---|---|---|

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp